ច្បាប់នេះការពារអ្នកម៉ៅការឯករាជ្យដែលធ្វើការឱ្យខ្លួនឯង ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិដោយមិនគិតពីស្ថានភាពអន្តោប្រវេសន៍។

អង្គភាពជួលពាណិជ្ជកម្មដែលស្ថិតនៅក្រោមច្បាប់នេះត្រូវតែអនុវត្តតាម។
ការសងសឹកគឺខុសច្បាប់។
មានប្រសិទ្ធិភាពនៅថ្ងៃទី 1 ខែកញ្ញា ឆ្នាំ 2022។

## សេចក្តីជូនដំណឹងអំពីសិទ្ធិ

# បទប្បញ្ញត្តិការពារអ្នកម៉ៅការឯករាជ្យ (Independent Contractor Protections Ordinance)

## អ្នកម៉ៅការឯករាជ្យមានសិទ្ធិ៖

- ទទួលបានការជូនដំណឹងជាលាយលក្ខណ៍អក្សរដែលកំណត់លក្ខខណ្ឌការងារដែលបានស្នើឡើង និងលក្ខខណ្ឌនៃការទូទាត់ប្រាក់ មុនពេលចាប់ផ្តើមការងារ។
- ទទួលបានការទូទាត់ប្រាក់ទាន់ពេលវេលា ស្របតាមលក្ខខណ្ឌនៃការជូនដំណឹងជាលាយលក្ខណ៍អក្សរ ឬកិច្ចសន្យាមុនការងារ។
- ប្រសិនបើទុកចោលដោយមិនមានការបញ្ជាក់ នោះត្រូវទទួលបានប្រាក់ទូទាត់ក្នុងរយៈពេល 30 ថ្ងៃបន្ទាប់ពីសេវាកម្មបានបញ្ចប់នៅក្រោមកិច្ចសន្យា។
- ត្រូវទទួលបានការជូនដំណឹងជាលាយលក្ខណ៍អក្សរដែលផ្តល់ព័ត៌មានអំពីការទូទាត់ជាក់លាក់នីមួយៗដោយមានរាយខ្ទង់ចំណាយជាក់លាក់ រាល់ពេលការទូទាត់ត្រូវបានធ្វើឡើង

## តើមានការគ្របដណ្តប់លើអ្នកណាខ្លះ?

**អ្នកម៉ៅការឯករាជ្យដែលធ្វើការដោយខ្លួនឯងដែល៖**

1. មិនមាននិយោជិត
2. បំពេញផ្នែកណាមួយនៃការងាររបស់ខ្លួនក្នុងទីក្រុង Seattle សម្រាប់អង្គភាពជួលពាណិជ្ជកម្ម

**និង**

3. នឹងទទួលបាន ឬអាចរំពឹងដោយសមហេតុផលថា នឹងទទួលបានសំណងសរុបយ៉ាងហោចណាស់ $600 ពីអង្គភាពជួលចន្លោះថ្ងៃទី 1 ខែមករា ដល់ថ្ងៃទី 31 ខែធ្នូ ក្នុងឆ្នាំដែលបានលើកឡើង។

## ដឹងពីសិទ្ធិជាកម្មករនិយោជិតរបស់អ្នក៖

- **ការសងសឹកត្រូវបានហាមឃាត់៖** ច្បាប់ទាំងនេះការពារកម្មករនិយោជិតមិនឱ្យរងការសងសឹកពីការប្រើប្រាស់ ឬអនុវត្តសិទ្ធិទាំងនេះ។
- **សិទ្ធិក្នុងការដាក់ពាក្យបណ្តឹង៖** កម្មករនិយោជិតមានសិទ្ធិប្តឹងតវ៉ាជាមួយការិយាល័យស្តង់ដារពលកម្ម (Office of Labor Standards) ឬដាក់ពាក្យបណ្តឹង ប្រសិនបើអង្គភាពជួលបំពានច្បាប់ទាំងនេះ។
- **សិទ្ធិការងារ៖** ប្រសិនបើអ្នកគិតថាអ្នកអាចជានិយោជិតជាជាងអ្នកម៉ៅការឯករាជ្យ សូមទាក់ទងការិយាល័យស្តង់ដារពលកម្ម។

  ក្នុងនាមជានិយោជិត អ្នកអាចមានសិទ្ធិទទួលបានពេលឈប់សម្រាកឈឺ ប្រាក់ឈ្នួលអប្បបរមា ប្រាក់បន្ថែមម៉ោង និងពេលអាហារថ្ងៃ និងពេលសម្រាកដោយមានប្រាក់ឈ្នួល។ សូមមើល ការណែនាំអំពីចំណាត់ថ្នាក់កម្មករ (Worker Classification Guide) មុនពេលទាក់ទងទៅ OLS ដើម្បីសួរសំណួរបន្ថែម។

  ការអនុវត្តសិទ្ធិរបស់អ្នកក្រោមបទប្បញ្ញត្តិការពារអ្នកម៉ៅការឯករាជ្យនឹងមិនប៉ះពាល់ដល់សិទ្ធិណាមួយដែលកម្មករនិយោជិតអាចមានក្នុងនាមជានិយោជិតនោះទេ។

## ផ្សេងទៀត

- អង្គភាពជួលត្រូវតែផ្តល់សេចក្តីជូនដំណឹងនេះទៅអ្នកម៉ៅការឯករាជ្យជាភាសាអង់គ្លេស និងភាសាចម្បងរបស់កម្មករនិយោជិត ក្នុងទម្រង់ជាច្បាប់ចម្លងបោះពុម្ព ឬទម្រង់អេឡិចត្រូនិកដែលអាចចូលមើលបានមុនពេលចាប់ផ្តើមធ្វើការ។
- ការិយាល័យស្តង់ដារពលកម្មផ្តល់ការបកប្រែជាសំណេរ ការបកប្រែផ្ទាល់មាត់និងការសម្របសម្រួលសម្រាប់ជនពិការ។

ស្កែនទីនេះដើម្បីអាន បទប្បញ្ញត្តិពេញលេញនិង សម្រាប់ព័ត៌មានបន្ថែម៖

10/22

## សូមទាក់ទងការិយាល័យស្តង់ដារពលកម្ម

**អ្នកម៉ៅការឯករាជ្យ៖** ដាក់ពាក្យបណ្តឹងជាមួយការិយាល័យស្តង់ដារពលកម្ម ឬដាក់ពាក្យបណ្តឹងនៅតុលាការ។
**អង្គភាពជួល៖** ទទួលបានជំនួយផ្នែកអនុលោមភាព និង/ឬទទួលបានការបណ្តុះបណ្តាល។

**206-256-5297** | Seattle Office of Labor Standards | **seattle.gov/laborstandards**

810 THIRD AVE, SUITE 375 SEATTLE, WA 98104 | ម៉ោងការងារ៖ 8 ព្រឹក – 5 ល្ងាច (ថ្ងៃចន្ទ – សុក្រ) | LABORSTANDARDS@SEATTLE.GOV